15.09.24
In 4063

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
លេខ.....០៧០.....អ.ស.ហ.ប្រក.

ប្រកាស
ស្តីពី
ការកែសម្រួលប្រការ១២ ប្រការ១៣ ប្រការ១៥ ប្រការ១៦ ប្រការ១៧ ប្រការ២២ និងប្រការ២៦ នៃប្រកាសលេខ ០៦៤ អ.ស.ហ.ប្រក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២២ ស្តីពីអាជីវកម្មផ្តល់សេវាកម្មអចលនវត្ថុ

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១២១/០០៣ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញប្រកាសលេខ ០០៨ អ.ស.ហ.ប្រក ចុះថ្ងៃទី១ ខែតុលា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃនាយកដ្ឋាន និងអង្គភាពក្រោមឱវាទរបស់និយ័តករអាជីវកម្មអចលនវត្ថុ និងបញ្ចាំ
- បានឃើញប្រកាសលេខ ០៦៤ អ.ស.ហ.ប្រក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២២ ស្តីពីអាជីវកម្មផ្តល់សេវាកម្មអចលនវត្ថុ
- យោងតាមសំណើរបស់អគ្គនាយកនៃនិយ័តករអាជីវកម្មអចលនវត្ថុ និងបញ្ចាំ

សម្រេច

ប្រការមួយ.-

ប្រការ១២ ប្រការ១៣ ប្រការ១៥ ប្រការ១៦ ប្រការ១៧ ប្រការ២២ និងប្រការ២៦ នៃប្រកាសលេខ ០៦៤ អ.ស.ហ.ប្រក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២២ ស្តីពីអាជីវកម្មផ្តល់សេវាកម្មអចលនវត្ថុ ត្រូវបានកែសម្រួលដូចតទៅ៖

ប្រការ១២.-ថ្មី

អ្នកឈរឈ្មោះលើអាជ្ញាបណ្ណសេវាកម្មអចលនវត្ថុ ត្រូវដាក់ពាក្យស្នើសុំបន្តសុពលភាពអាជ្ញាបណ្ណមក **ន.អ.ប**. ឱ្យបានយ៉ាងតិច ៣០ (សាមសិប) ថ្ងៃ មុនកាលបរិច្ឆេទផុតសុពលភាពអាជ្ញាបណ្ណ ដោយបំពេញលក្ខខណ្ឌជាអាទិ៍ ដូចខាងក្រោម៖

- លិខិតស្នើសុំបន្តសុពលភាពអាជ្ញាបណ្ណ តាមគំរូរបស់ **ន.អ.ប**.
- អាជ្ញាបណ្ណច្បាប់ដើម
- បណ្ណពន្ធប៉ាតង់ និងឯកសារបញ្ជាក់ការបង់ពន្ធ
- ធានារ៉ាប់រងការៈទទួលខុសត្រូវវិជ្ជាជីវៈចេញដោយក្រុមហ៊ុនធានារ៉ាប់រងក្នុងស្រុកណាមួយ ដែលមានតម្លៃសមមូលនឹងទឹកប្រាក់ចំនួន ២០០.០០០ (ពីរសែនដុល្លារអាមេរិក ចំពោះក្រុមហ៊ុនគ្រប់គ្រងអចលនវត្ថុ និងក្រុមហ៊ុនវាយតម្លៃ លើកលែងតែក្រុមហ៊ុនភ្នាក់ងារអចលនវត្ថុដែលត្រូវឈរលើគោលការណ៍ស្មគ្រចិត្ត
- លក្ខខណ្ឌតម្រូវផ្សេងទៀតដែលត្រូវកំណត់ដោយ **ន.អ.ប**.។

ការបន្តសុពលភាពអាជ្ញាបណ្ណ ត្រូវបង់កម្រៃអាជ្ញាបណ្ណ និងកម្រៃសេវារដ្ឋបាល ដូចមានកំណត់ក្នុងតារាងនៃប្រការ១៦ ថ្មី នៃប្រកាសនេះ និងត្រូវបង់ចូលគណនីរបស់ **ន.អ.ប**.។

ប្រការ១៣.-ថ្មី

ក្រុមហ៊ុនត្រូវដាក់ពាក្យស្នើសុំបន្តសុពលភាពវិញ្ញាបនបត្រវិជ្ជាជីវៈមក **ន.អ.ប**. ឱ្យបានយ៉ាងតិច ៣០ (សាមសិប) ថ្ងៃ មុនកាលបរិច្ឆេទផុតសុពលភាពនៃវិញ្ញាបនបត្រវិជ្ជាជីវៈ ដោយបំពេញលក្ខខណ្ឌ ជាអាទិ៍ ដូចខាងក្រោម៖

- លិខិតស្នើសុំបន្តសុពលភាពវិញ្ញាបនបត្រវិជ្ជាជីវៈ តាមគំរូរបស់ **ន.អ.ប**.
- វិញ្ញាបនបត្រវិជ្ជាជីវៈច្បាប់ដើម
- លក្ខខណ្ឌតម្រូវផ្សេងទៀត ដែលត្រូវកំណត់ដោយ **ន.អ.ប**.។

ការបន្តសុពលភាពវិញ្ញាបនបត្រវិជ្ជាជីវៈ ត្រូវបង់កម្រៃវិញ្ញាបនបត្រវិជ្ជាជីវៈ និងកម្រៃសេវារដ្ឋបាល ដូចមានកំណត់ក្នុងតារាងនៃប្រការ១៦ ថ្មី នៃប្រកាសនេះ និងត្រូវបង់ចូលគណនីរបស់ **ន.អ.ប**.។

ប្រការ១៥.-ថ្មី

ន.អ.ប. មានសិទ្ធិសម្រេចផ្តល់ ឬបដិសេធចំពោះការស្នើសុំអាជ្ញាបណ្ណ និង/ឬវិញ្ញាបនបត្រវិជ្ជាជីវៈ ក្នុងរយៈពេល ៦ (ប្រាំមួយ) ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលបានសំណុំឯកសារត្រឹមត្រូវ និងគ្រប់ចំនួន តាមលក្ខខណ្ឌតម្រូវរបស់ **ន.អ.ប**.។

ក្នុងករណី **ន.អ.ប**. បដិសេធចំពោះការស្នើសុំអាជ្ញាបណ្ណ និង/ឬវិញ្ញាបនបត្រវិជ្ជាជីវៈ ត្រូវជូនដំណឹងទៅអ្នកស្នើសុំដោយបញ្ជាក់ហេតុផលជាលាយលក្ខណ៍អក្សរ។

ប្រការ១៦.-ថ្មី

កម្រៃ និងសុពលភាពអាជ្ញាបណ្ណ និងវិញ្ញាបនបត្រវិជ្ជាជីវៈ ត្រូវបានកំណត់ទៅតាមប្រភេទសេវាកម្ម ដូចខាងក្រោម៖

តម្លៃគិតជារៀល

ប្រភេទ	កម្រៃអាជ្ញាបណ្ណ (ថ្មី/បន្តសុពលភាព)	កម្រៃសេវារដ្ឋបាល (ថ្មី/បន្តសុពលភាព)	សុពលភាព
អាជ្ញាបណ្ណគ្រប់គ្រងអចលនវត្ថុ	៤៥0.000	១២៦.000	១ ឆ្នាំ
អាជ្ញាបណ្ណវាយតម្លៃ	៤៥0.000	១២៦.000	១ ឆ្នាំ
អាជ្ញាបណ្ណភ្នាក់ងារអចលនវត្ថុ	៤៥0.000	១២៦.000	១ ឆ្នាំ
អាជ្ញាបណ្ណគ្រប់គ្រងអចលនវត្ថុ (សាខា)	២៧0.000	៨១.000	១ ឆ្នាំ
អាជ្ញាបណ្ណវាយតម្លៃ (សាខា)	២៧0.000	៨១.000	១ ឆ្នាំ
អាជ្ញាបណ្ណភ្នាក់ងារអចលនវត្ថុ (សាខា)	២៧0.000	៨១.000	១ ឆ្នាំ
វិញ្ញាបនបត្រវិជ្ជាជីវៈវាយតម្លៃ	១៨0.000	៥៤.000	១ ឆ្នាំ
វិញ្ញាបនបត្រវិជ្ជាជីវៈភ្នាក់ងារអចលនវត្ថុ	១៨0.000	៥៤.000	១ ឆ្នាំ

កម្រៃអាជ្ញាបណ្ណ និងវិញ្ញាបនបត្រវិជ្ជាជីវៈ ឬកម្រៃបន្តសុពលភាពអាជ្ញាបណ្ណ និងវិញ្ញាបនបត្រវិជ្ជាជីវៈ និងកម្រៃសេវារដ្ឋបាល ដូចមានចែងក្នុងប្រការនេះ ត្រូវបង់ទៅក្នុងគណនីរបស់ **ន.អ.ប**.។

ប្រការ១៧.-ថ្មី

ក្រុមហ៊ុនត្រូវចូលរួមបង់ភាគទានប្រចាំឆ្នាំសម្រាប់គាំទ្រដល់មូលនិធិទ្រទ្រង់ និងអភិវឌ្ឍវិស័យអចលនវត្ថុ និងវិស័យបញ្ចាំ ដូចខាងក្រោម៖

តម្លៃគិតជារៀល

ប្រភេទ	ភាគទាន
អាជ្ញាបណ្ណគ្រប់គ្រងអចលនវត្ថុ	១២៦.០០០
អាជ្ញាបណ្ណវាយតម្លៃ	១២៦.០០០
អាជ្ញាបណ្ណភ្នាក់ងារអចលនវត្ថុ	១២៦.០០០
អាជ្ញាបណ្ណគ្រប់គ្រងអចលនវត្ថុ (សាខា)	៨១.០០០
អាជ្ញាបណ្ណវាយតម្លៃ (សាខា)	៨១.០០០
អាជ្ញាបណ្ណភ្នាក់ងារអចលនវត្ថុ (សាខា)	៨១.០០០
វិញ្ញាបនបត្រវិជ្ជាជីវៈវាយតម្លៃ	៥៤.០០០
វិញ្ញាបនបត្រវិជ្ជាជីវៈភ្នាក់ងារអចលនវត្ថុ	៥៤.០០០

កម្រៃភាគទានដូចមានកំណត់ក្នុងតារាងខាងលើ ត្រូវបង់ទៅក្នុងគណនីរបស់ **ន.អ.ប**.។

ប្រការ២២.-ថ្មី

រាល់ការផ្លាស់ប្តូរទីតាំងអាជីវកម្ម នាមករណ៍ ភាគហ៊ុនិក សមាសភាពក្រុមប្រឹក្សាភិបាល អ្នកឈរឈ្មោះលើអាជ្ញាបណ្ណ ឬអ្នកឈរឈ្មោះលើវិញ្ញាបនបត្រវិជ្ជាជីវៈរបស់ក្រុមហ៊ុន ឬសាខាក្រុមហ៊ុន ត្រូវមានការឯកភាពជាគោលការណ៍ជាមុនពី **ន.អ.ប**.។

ក្រុមហ៊ុន ត្រូវដាក់សំណើជាលាយលក្ខណ៍អក្សរមក **ន.អ.ប**. មុននឹងធ្វើការផ្លាស់ប្តូរ និងត្រូវបង់កម្រៃសេវារដ្ឋបាលចំនួន ១៨០.០០០ (មួយរយប៉ែតសិបពាន់) រៀល ក្នុង ១ (មួយ) ករណី។

កម្រៃសេវារដ្ឋបាល ដូចមានចែងក្នុងប្រការនេះ ត្រូវបង់ទៅក្នុងគណនីរបស់ **ន.អ.ប**.។

ន.អ.ប. ត្រូវជូនដំណឹងអំពីការអនុញ្ញាត ឬបដិសេធ ក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលបានសំណុំឯកសារត្រឹមត្រូវ និងគ្រប់ចំនួនតាមលក្ខខណ្ឌតម្រូវរបស់ **ន.អ.ប**.។

ប្រការ២៦.-ថ្មី

ន.អ.ប. ត្រូវចេញលិខិតបញ្ជាក់ការយល់ព្រម ឬបដិសេធសំណើរបស់ក្រុមហ៊ុន បន្ទាប់ពីការត្រួតពិនិត្យសំណុំឯកសារ និង/ឬការវាយតម្លៃជាក់ស្តែងពីមន្ត្រីជំនាញរបស់ **ន.អ.ប**. ក្នុងរយៈពេលយ៉ាងយូរ ៦ (ប្រាំមួយ) ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលបានសំណុំឯកសារត្រឹមត្រូវ និងគ្រប់ចំនួនតាមលក្ខខណ្ឌតម្រូវរបស់ **ន.អ.ប**.។

ប្រការពីរ.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

ប្រការបី.-

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ អគ្គនាយកនៃនិយ័តករអាជីវកម្មអចលនវត្ថុ និងបញ្ចាំ អគ្គនាយកនៃនិយ័តករ ប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ និងបុគ្គលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ ពុធ ៤ កើត ខែ ភទ្របទ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ២០២៦

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ



អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

កន្លែងទទួលៈ
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងយុត្តិធម៌
-ធនាគារជាតិនៃកម្ពុជា
-ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
-គ្រប់អង្គភាពនិងសមាសភាពក្រុមប្រឹក្សានៃ អ.ស.ហ.
"ដើម្បីជូនជ្រាប"
-ដូចប្រការបី "ដើម្បីអនុវត្ត"
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ